# ការដោះសារ (excuse)

ការដោះសារ គឺមូលដ្ឋាននាំឲ្យមិនទទួលខុសត្រូវព្រហ្មទណ្ឌ។ ការដោះសារ មានដូចជា ស្ថានភាពចាំបាច់ (necessity) ការបង្ខំ (duress) រោគចិត្ត (mental defect/disease) ការញៀន (intoxication) ការច្រឡំអង្គហេតុ (mistake of fact) និងការច្រឡំអង្គច្បាប់ (mistake of law)។

ជនសមគំនិត (accomplice) នឹងមិនរួចផុតពីការទទួលខុសត្រូវទេ ទោះបី ជនដៃដល់ (perpetrator) រួចផុត ដោយផ្អែកលើមូលដ្ឋានដោះសារក្តី។

ស្ថានភាពចាំបាច់ និងការបង្ខំមានភាពខុសគ្នា។ ការបង្ខំ កើតមានពីសកម្មភាពរបស់មនុស្ស រីឯស្ថានភាពចាំបាច់ កើតចេញពីកត្តាខាងក្រៅមនុស្ស។ ICTY មិនទទួលយកការបង្ខំ ជាការដោះសារសម្រាប់បទឧក្រិដ្ឋកម្មសង្គ្រាម (war crime) និង បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (crime against humanity) ទេ (Erdemovic,IT-96-22-A, 1997)។ ក្នុងការសម្រេច វាទាមទារឲ្យមានការថ្លឹងថ្លែងរវាងទង្វើរបស់អ្នកប្រព្រឹត្ត និងអ្វីដែលចង់ការពារ។

សម្រាប់ រោគចិត្ត វាត្រូវស្ថិតនៅក្នុងកម្រិតមួយធ្ងន់ធ្ងរ ប៉ះដល់សមត្ថភាពក្នុងការវាយតម្លៃ ភាពមិនស្របច្បាប់នៃអំពើរបស់ខ្លួន។ ការណ៍គ្រាន់ត្រឹមតែប៉ះពាល់តិចតួចដល់ផ្លូវចិត្ត ដែលបន្ថយនូវការទទួលខុសត្រូវផ្លូវចិត្ត (diminished mental responsibility) អាចទទួលបាននូវការសម្រាលទោស។ ករណីខាងក្រោយនេះ វាអាចកើតមកពីការញៀន ហើយប្រសិនបើការញៀននេះដោយចេតនា ការដោះសារ នឹងមិនអាចទទួលយកបានទេ។

ការច្រឡំអង្គហេតុ អាចជាការដោះសារ ប្រសិនបើវានាំឲ្យបាត់នូវធាតុអត្តនោម័ត (*mens rea*) នៃបទល្មើស ហើយការច្រឡំនេះសមហេតុផល។ តុលាការ ជាទូទៅ បដិសេធ នូវការច្រឡំអង្គហេតុ ជាការដោះសារ ដោយសារការធ្វេសប្រហែស (negligence) និង ការខ្ជីខ្ជា (recklessness) របស់បុគ្គលជាជនល្មើស (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 317-320)។